**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៦៤៦.....សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
- យោងតាមសំណូមពរការងារចាំបាច់

## <u>សម្រេច</u>

**ប្រការ ១.-**

បង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ហៅកាត់ថា លេខាធិការដ្ឋាន គជសដ (National Cross-Border Transport Facilitation Committee – NCTFC Secretariat)។ លេខាធិការដ្ឋាននេះមានទីតាំងនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់បម្រើការងាររបស់ខ្លួន ស្របតាមបញ្ញត្តិមាត្រា ១ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែនដូចយោងខាងលើ ។

**ប្រការ ២.-**

លេខាធិការដ្ឋាន គជសដ មានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករ ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក សៀង ឈុនទ្រី | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២- បណ្ឌិត គុណ ញឹម | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ៣-បណ្ឌិត ប៉ែន សំអាត | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ | អនុប្រធាន |
| ៤- លោក នួន ច័ន្ទរិទ្ធ | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | អនុប្រធាន |
| ៥- លោក អ៊ុយ សារិន | ប្រធាននាយកដ្ឋានរបបគយ | អនុប្រធាន |
| ៦- លោក ប៊ូរ ប៊ុនណារ៉ា | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៧- បណ្ឌិត សង់ស៊ីណាវិទ្យ | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៨- លោក សុខ សុវិទ្យា | អនុប្រធានទទួលបន្ទុករួមការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៩- លោក យិន សុឌីណា | អនុប្រធានទទួលបន្ទុករួមការិយាល័យកិច្ចការអន្តរជាតិ | សមាជិក |
| ១០-លោក សែម ម៉េង | អនុប្រធានការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ | លេខាអចិន្ត្រៃយ៍ |
| ១១- លោក ហ៊ុល ប៊ុនថា | អនុប្រធានការិយាល័យគោលនយោបាយ និងគ្រប់គ្រងតំបន់រួចពន្ធ | សមាជិក |
| ១២- លោក សុខ ទ្រី | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៣- លោក យុត វីរៈខឹម | ជំនួយការការិយាល័យត្រួតពិនិត្យ | សមាជិក |
| ១៤- លោក ជា សំណាង | ភ្នាក់ងារគយនិងរដ្ឋាករការិយាល័យបច្ចេកទេសគយ | សមាជិក |
| ១៥- លោក លន ចិត្រា | ភ្នាក់ងារគយនិងរដ្ឋាករការិយាល័យបច្ចេកទេសគយ | សមាជិក |

**ប្រការ ៣.-**

លេខាធិការដ្ឋាន គជសដ មានភារកិច្ច ដូចខាងក្រោម ៖

- ជាចំណុចទាក់ទងសម្រាប់សម្របសម្រួលការងារនានារបស់ គជសដ ជាមួយស្ថាប័ន និងបុគ្គលពាក់ព័ន្ធ ឲ្យដំណើរការប្រកបដោយប្រសិទ្ធភាព តាមតួនាទី ភារកិច្ច និងសិទ្ធិរបស់ គជសដ តាមបញ្ញត្តិមាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។
- ជាសេនាធិការរបស់ គជសដ លើការងារស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃនូវនីតិវិធី និងបទប្បញ្ញត្តិច្បាប់ជាធរមាន ពាក់ព័ន្ធនឹងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវទំនិញ មធ្យោបាយដឹកជញ្ជូន និងអ្នកដំណើរ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ ។ ក្នុងករណីចាំបាច់ ត្រូវរៀបចំនូវសេចក្តីព្រាងបទប្បញ្ញត្តិដែលមានប្រសិទ្ធភាពជាង ហើយដាក់ជូន គជសដ ដើម្បីពិនិត្យលទ្ធភាពសុំការសម្រេចពីរាជរដ្ឋាភិបាល ។
- ចាត់ចែងផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់បុគ្គលពាក់ព័ន្ធ ជាពិសេសសហគមន៍ធុរកិច្ចឲ្យមានការយល់ដឹងច្បាស់លាស់អំពីនីតិវិធី និងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- ទទួល ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំ គជសដ នូវរាល់សំណូមពរ ឬការតវ៉ានានារបស់បុគ្គលពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន តាមបទប្បញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ ។

- ចូលរួមរៀបចំកិច្ចប្រជុំនានារបស់ គជសដ និងចូលរួមកសាងកញ្ចប់ថវិកាមួយដោយឡែក ក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានានិរន្តរភាពនៃកិច្ចប្រតិបត្តិការ និងមុខងារនៃ គជសដ ។
- ធ្វើរបាយការណ៍ជាប្រចាំពីវឌ្ឍនភាពនានា នៃកិច្ចដំណើរការរបស់ គជសដ និងរបាយការណ៍ផ្សេងទៀតតាមការកំណត់របស់ប្រធាន គជសដ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាន គជសដ ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ